**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃអង្គារ ៦កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ជំនួបពិភាក្សាការងារ រវាង
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយលោក ស្កត ម៉ូរីស
# (Scott Morris) អនុប្រធាន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

កាលពីរសៀលថ្ងៃទី ១៦ ខែមករា ឆ្នាំ ២០២៤ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក **ស្កត ម៉ូរីស** (Scott Morris) អនុប្រធាន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចនៅកម្ពុជា របស់លោក **ស្កត ម៉ូរីស** ចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ២០ ខែមករា ឆ្នាំ ២០២៤ ក្នុងគោលបំណង ដើម្បីបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាង ADB ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះលោក **ស្កត ម៉ូរីស** និងសហការី ក្នុងឱកាសបំពេញការងារនៅប្រទេសកម្ពុជា និងបានវាយតម្លៃខ្ពស់ ចំពោះការចូលរួមចំណែកដ៏សំខាន់ របស់ ADB ដែលបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អ និងរឹងមាំ ក្នុងការគាំទ្រកម្ពុជា ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច អស់រយៈពេលជាង ៣០ ឆ្នាំកន្លងទៅ, ជាពិសេស ADB បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយរាជរដ្ឋាភិបាលកម្ពុជា ឆ្លើយតបភ្លាមៗក្នុងកាលៈទេសៈដ៏លំបាក ដែលក្នុងនោះ រួមមាន ការសម្រេចផ្តល់ហិរញ្ញប្បទាន ជូនរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងការបន្តគាំទ្ររាជរដ្ឋាភិបាល ក្នុងការស្តារឡើងវិញ នូវសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ តាមរយៈការអនុវត្ត “**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ ឆ្នាំ២០២១-២០២៣**” ។

លោក **ស្កត ម៉ូរីស** បានថ្លែងកោតសរសើរ ចំពោះភាពជោគជ័យលើសមរភូមិប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា កន្លងទៅនេះ និងបានថ្លែងអបអរសាទរ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដែលត្រូវបានតែងតាំងបន្តជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាទេសាភិបាលរបស់កម្ពុជាប្រចាំ ADB ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ។ លោក **ស្កត ម៉ូរីស** ក៏បានគូសរំលេចឡើងវិញ នូវការប្តេជ្ញាចិត្ត របស់ ADB ក្នុងការបន្តជួយកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ ដូចមានចែងក្នុង**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់សុភវិនិច្ឆ័យរបស់លោក **ស្កត ម៉ូរីស** និងបានមានប្រសាសន៍ថា ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វ ឆ្លាតវៃ និងម៉ឺងម៉ាត់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ នៃរដ្ឋសភា បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដោយផ្តោតលើអាទិភាពគន្លឹះ ចំនួន ៥ គឺ **មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យាឌីជីថល** និងមានគោលដៅយុទ្ធសាស្ត្រចំនួន ៥ គឺ ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រមាណ ៧% ក្នុងមួយឆ្នាំ, ការ

បង្កើនការងារ (ទាំងបរិមាណ និងគុណភាព), ការកាត់បន្ថយភាពក្រីក្រ, ការពង្រឹងប្រសិទ្ធភាពការងារ និងចីរភាពនៃការអភិវឌ្ឍសង្គមជាតិ និងការកសាងភាពធន់ ។ ឯកឧត្តមក៏បានថ្លែងអំណរគុណដល់ ADB សម្រាប់ការរួមចំណែក ក្នុងការគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ដែលនេះជារបៀបវារៈមួយនៃ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** សំដៅពង្រឹងភាពប្រកួតប្រជែង និងជំរុញល្បឿននៃកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាបន្ន ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានសាទរចំពោះការសន្យារបស់ ADB ក្នុងការកៀរគរហិរញ្ញវត្ថុអាកាសធាតុ និងការប្តេជ្ញាចិត្តខ្ពស់ របស់ ADB ក្នុងការដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ ក្នុងតំបន់សម្រាប់ឆ្នាំ ២០១៩-២០៣០ ដែលក្នុងនោះ ក៏រួមមានប្រទេសកម្ពុជាផងដែរ ។ ទោះជាយ៉ាងណា, ការលើកកម្ពស់ការអភិវឌ្ឍបៃតងក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវផ្អែកលើអភិក្រម **"រក្សាតុល្យការរវាងកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាបន្ន ជាមួយនឹងតម្រូវការបៃតង"** ។ បន្ថែមលើនេះ, ឯកឧត្តម ក៏បានស្នើ ADB បន្តគាំទ្រគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យអាទិភាពមួយចំនួន មានជាអាទិ៍÷ (១). ការអភិវឌ្ឍវិស័យថាមពល, (២). ការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីអាចធានាសន្តិសុខស្បៀងផង និងជំរុញការធ្វើពាណិជ្ជូបនីយកម្មផង, (៣). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង ដោយផ្តោតជាពិសេស លើការរៀបចំប្រព័ន្ធលូ, ប្រព័ន្ធប្រព្រឹត្តកម្ម និងការគ្រប់គ្រងសំណល់ផ្សេងៗ ដោយមានការរៀបចំផែនការមេ និងផែនការវិនិយោគច្បាស់លាស់ រួមទាំងការគិតគូរអំពីយន្តការស្រង់ថ្លៃដើម, ថ្លៃវិនិយោគ (Cost recovery) និងនិរន្តរភាពប្រតិបត្តិការផងដែរ, និង (៤). ការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព តាមរយៈការវិនិយោគសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលមានសមត្ថភាពបម្រើឱ្យមុខងារសំខាន់យ៉ាងហោច ៣ រួមមាន មុខងារគ្រប់គ្រងគ្រោះមហន្តរាយ, មុខងារស្រោចស្រពកសិកម្ម និងមុខងារជាប្រភពទឹកសម្រាប់ការផលិតទឹកស្អាតបម្រើឱ្យជីវភាពរស់នៅរបស់ប្រជាជន និង ការអភិវឌ្ឍវិស័យឧស្សាហកម្ម ។

ក្នុងជំនួបពិភាក្សានេះដែរ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណដល់ ADB ចំពោះការយកចិត្តទុកដាក់ និងការរួមចំណែក ក្នុងការអភិវឌ្ឍវិស័យឯកជននៅកម្ពុជា ដោយស្នើឱ្យ ADB គិតគូរអំពីការជំរុញការផ្តល់ឥណទានដល់វិស័យឯកជន ក្រោមក្របខណ្ឌជា Non-Sovereign Loan ដើម្បីបង្កើនប្រសិទ្ធភាព និងសម្រេចបាននូវគោលដៅអាទិភាពនៃការអភិវឌ្ឍ ។

នៅទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអបអរសាទរចំពោះការដាក់ឱ្យអនុវត្តប្រព័ន្ធប្រតិបត្តិការថ្មី (New Operating Model) របស់ ADB ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងកិច្ចសហប្រតិបត្តិការ ព្រមទាំងថ្លែងអំណរគុណចំពោះការបង្កើនធនធានហិរញ្ញប្បទានបន្ថែមដល់កម្ពុជា និងបានជូនពរលោក **ស្កុត ម៉ូរីស** ព្រមទាំងសហការី ឱ្យទទួលបានជោគជ័យក្នុងដំណើរទស្សនកិច្ចរបស់ខ្លួននៅកម្ពុជា ។